ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ០៥១ អឃស.មភ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៥

# សារាចរណែនាំ

## ស្តីពី

## ការប្រើប្រាស់ផ្លាកសញ្ញាសំគាល់រថយន្តគិលានសង្គ្រោះបន្ទាន់

រយៈកាលកន្លងមកក្រសួងសុខាភិបាលបានសង្កេតឃើញថា រថយន្តគិលានសង្គ្រោះបន្ទាន់របស់រដ្ឋ និងគ្លីនិកឯកជនមួយចំនួនបានប្រើប្រាស់ផ្លាកសញ្ញាសំគាល់រថយន្តគិលានសង្គ្រោះ ( Ambulance ) មិនត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាលឡើយ ព្រមទាំងសរសេរផ្សព្វផ្សាយពាណិជ្ជកម្មលើតួរថយន្ត ស្តីពីសេវាបញ្ជូនជំងឺទៅព្យាបាលនៅប្រទេសក្រៅថែមទៀត ។

ដើម្បីរក្សានូវសណ្តាប់ធ្នាប់ សុវត្ថិភាព សេចក្តីថ្លៃថ្នូរ សមស្របតាមក្រមសីលធម៌គ្រូពេទ្យ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដល់លោក លោកស្រី ប្រធានមន្ទីរពេទ្យជាតិ ប្រធានមជ្ឈមណ្ឌលជាតិ ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ជាពិសេសម្ចាស់គ្លីនិកឯកជនទាំងអស់ឱ្យគោរពតាមសេចក្តីណែនាំដូច ខាងក្រោមនេះ :

១-<u>ចំពោះរថយន្តគិលានសង្គ្រោះរបស់រដ្ឋ:</u>

-ត្រូវបំពាក់លេខរាជការឱ្យបានត្រឹមត្រូវ

-ត្រូវសរសេរអក្សររថយន្តគិលានសង្គ្រោះ និងឈ្មោះមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលជាតិ ជាអក្សរពណ៌ក្រហមលើតួរថយន្តពណ៌ស ជាភាសាខ្មែរអមដោយអក្សរបារាំង ឬ អង់គ្លេស នៅពីក្រោមអក្សរខ្មែរ ដោយមានទំហំអក្សរសរសេរឱ្យបានសមរម្យទៅ និងផ្ទៃជញ្ជាំងរថយន្តព្រមទាំងបិតផ្លាកសញ្ញា Logo សង្គ្រោះបន្ទាន់លើផ្ទៃ នៃជញ្ជាំងរថយន្តទាំងសងខាង

-ហាមបើកភ្លើង ឬស៊ីរ៉ែន ដើម្បីធ្វើសារាចរតាមផ្លូវ ដោយគ្មានករណីសង្គ្រោះបន្ទាន់

-ហាមយករថយន្តគិលានសង្គ្រោះទៅធ្វើដំណើរកំសាន្តជាលក្ខណៈគ្រួសារ និងដឹកសំភារៈផ្សេងៗក្រៅពីអ្នកជំងឺ ។

២-<u>ចំពោះរថយន្តគិលានសង្គ្រោះរបស់គ្លីនិកឯកជន:</u>

-ត្រូវសរសេរអក្សររថយន្តគិលានសង្គ្រោះ និងឈ្មោះគ្លីនិកជាអក្សរពណ៌ខៀវទឹកប៊ិច ជាភាសាខ្មែរ អមដោយអក្សរបារាំងឬអង់គ្លេស នៅពីខាងក្រោមអក្សរខ្មែរ ដោយមានទំហំអក្សរសរសេរឱ្យបានសមរម្យទៅ និងផ្ទៃជញ្ជាំងរថយន្តពណ៌ស និងមានសញ្ញាកាកបាទពណ៌ខៀវទឹកប៊ិចអមសងខាងអក្សរ



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

-ត្រូវមានប័ណ្ណសំគាល់ និងស្លាកលេខបានយន្តត្រឹមត្រូវ ដែលចេញដោយក្រសួងសាធារណការ

-គ្រប់ម្ចាស់គ្លីនិកឯកជនទាំងអស់ដែលមានរថយន្តពិលានសង្គ្រោះត្រូវយករថយន្តពិលានសង្គ្រោះ របស់
ការត្រួតពិនិត្យ និងចុះបញ្ជិកានៅក្រសួងសុខាភិបាល ( នាយកដ្ឋានមន្ទីរពេទ្យ ) ដើម្បីសុំផ្លាកសញ្ញា Logo

-ហាមប្រើប្រាស់រថយន្តពិលានសង្គ្រោះ ទៅដឹកព្រួសារដើរកំសាន្ត ឬប្រកបរបរ រកស៊ីដឹកសំភារៈផ្សេងៗ

-ហាមប្រើប្រាស់រថយន្តពិលានសង្គ្រោះទៅដឹកអ្នករងគ្រោះដោយគ្រោះថ្នាក់ចរាចរ ឬឧបទ្ទវហេតុផ្សេងៗ

-ហាមសរសេរអក្សរ ឬពាក្យពេចន៍ ផ្សព្វផ្សាយពាណិជ្ជកម្ម ឬផ្លាកសំគាល់ផ្សេងៗលើរថយន្តពិលានសង្គ្រោះ

-ករណីម្ចាស់គ្លីនិកឯកជនណាមួយ មិនគោរពតាមសារាចរណែនាំខាងលើនេះ ក្រសួងសុខាភិបាលនឹងមាន
តាមនិតិវិធីនៃច្បាប់ ។

ទទួលបានសារាចរនេះ គ្រប់ប្រធានមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរសុខាភិបាល រាជធានី-ខេត្ត និង ម្ចាស់គ្លីនិក ឯកជនទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ម៉ម ប៊ុនហេង

<u>ចម្លងជូន:</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងយុត្តិធម៌

-សាលារាជធានី-ខេត្ត

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

-លេខាធិការដ្ឋានលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់

-ឯកសារ-កាលប្បវត្តន៍